

# ខ្ញុំចង់ក្លាយជា

Belgian Development Cooperation

Let's Read

The Asia Foundation

ពាក្យថ្មីនៅក្នុងសៀវភៅនេះ៖ គោក ចិញ្ចឹម ជញ្ជូន ឈើហ៊ុប ត្រីបាឡែន នឿយ មាឌ យ៉ាងងាយ រូបរាង សម្លាប់ សេក សក ស្រកា ហោះហើរ អូស



កែវ និងសុផាជាមិត្តនឹងគ្នា ។ ថ្ងៃមួយកុមារទាំងពីរ បានជួបគ្នា
នៅក្រោមដើមឈើមួយ ហើយនិយាយ ប្រាប់គ្នាអំពីរឿងសត្វ ។



សុផានិយាយៈ ”ខ្ញុំចង់កើតជាត្រីបាឡែន ។ បើខ្ញុំជាត្រីបាឡែន ខ្ញុំនឹងមានមាឌធំហើយត្រី ទាំងអស់នឹងខ្លាចខ្ញុំ” ។



បើខ្ញុំជាត្រីបាឡែន នឹងមានមនុស្សច្រើន ទៅលេងសមុទ្រដើម្បី
មើលខ្ញុំ ។



ប៉ុន្តែខ្ញុំខ្លាចមនុស្សតាមសម្លាប់ខ្ញុំ ។



កែវឆ្លើយ៖ ”ចំណែកខ្ញុំមិនចង់កើតជាត្រីបាឡែនទេ ។ ខ្ញុំចង់កើតជាសត្វសេកវិញ ព្រោះខ្ញុំនឹងមានរូបរាងស្អាត ហើយអាចហោះហើរបាន” ។



បើខ្ញុំជាសត្វសេក គេនឹងយកខ្ញុំទៅចិញ្ចឹមនៅផ្ទះ ។



ប៉ុន្តែបើខ្ញុំរស់នៅក្នុងផ្ទះ គេនឹងទុកខ្ញុំក្នុងទ្រុង ហើយខ្ញុំនឹងមិន
អាចហោះហើរបានទេ ។



កែវនិយាយ៖ ”ខ្ញុំមិនចង់កើតជាសត្វសេកទេ” ។



សុផាបន្ត៖ ”ខ្ញុំចង់កើតជាសត្វដំរីវិញ ព្រោះខ្ញុំនឹងមានមាឌធំ ហើយខ្លាំង” ។



ខ្ញុំនឹងមិនខ្លាចសត្វផ្សេងៗទៀតទេ ប៉ុន្តែសត្វផ្សេងៗទៀតនឹង
ខ្លាចខ្ញុំ ។



ខ្ញុំអាចអូសឈើហ៊ុបធំៗ និងដឹកជញ្ជូនមនុស្ស បានយ៉ាងងាយ ។



ប៉ុន្តែបើខ្ញុំដឹកជញ្ជូនមនុស្សរហូត ខ្ញុំមិនសប្បាយចិត្តទេ ព្រោះខ្ញុំនឿយហត់ណាស់ ។



កែវនិយាយ៖ ”ខ្ញុំមិនចង់កើតជាសត្វដំរីទេ” ។ ខ្ញុំចង់កើតជាសត្វពស់វិញព្រោះខ្ញុំអាចរស់នៅលើគោកផង និងក្នុងទឹកផង ។



បើខ្ញុំជាសត្វពស់ ខ្ញុំអាចសកស្រកាពេលខ្ញុំចាស់ ។ មានតែខ្ញុំទេ
ដែលអាចធ្វើយ៉ាងដូចនេះបាន ។



បើខ្ញុំជាសត្វពស់ មនុស្សនឹងខ្លាចខ្ញុំ ហើយតាមសម្លាប់ខ្ញុំ ។



កុមារទាំងពីរនិយាយៈ "អូ! គិតៗទៅកើតជាសត្វ ពិបាកណាស់ ។ យើងនៅជាកុមារវិញល្អជាង" ។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ខ្ញុំចង់ក្លាយជា*, Author: Belgian Development Cooperation. Published by Ministry of Education, Youth, and Sports of Cambodia, © Ministry of Education, Youth, and Sports of Cambodia.

Translations: © The Asia Foundation, 2018.